

កុមារចូលរួមដាក់ពិន្ទុលើសេវាសាលាបឋមសិក្សា នៅឃុំគ ស្រុកព្រៃឈរ

# ព្រឹត្តិបត្រលើកទី ៩

## គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខ៩ សម្រាប់ខែ មករា - មីនា ឆ្នាំ២០១៥

### ប្រជាពលរដ្ឋ និងគណនេយ្យភាពសង្គម

អង្គការផេក(ដោយគាំទ្រថវិកាពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍរបស់ប្រទេសស៊ុយអែត) និងលេខាធិការដ្ឋាន គ.ជ.អ.ប គាំទ្រថវិកាដោយអង្គការយូនីសែហ្វ បានចាប់ដៃគូគាំទ្រ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការតាមដានវាយតម្លៃទៅលើសកម្មភាព និងការផ្តល់សេវារបស់ក្រុមប្រឹក្សា មណ្ឌលសុខភាព និងសាលាបឋមសិក្សាក្នុងឃុំចំនួន៤៣ នៃស្រុកចំនួន ៥ គឺស្រុកក្រគរ ស្រុកសង្កែ ស្រុកថ្មគោល ស្រុកព្រៃឈរ និងស្រុកពេជ្រាដា។

គម្រោងនេះ ចាប់ផ្តើមពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ និងសម្របសម្រួលដោយអង្គការដៃគូរបស់ផេក ដូចជា៖ អង្គការអមរា ទ្រទ្រង់ភូមិអនាគតកុមារ ភ្នំស្រីដើម្បីអភិវឌ្ឍន៍ និងអង្គការភូមិខ្ញុំ។

គម្រោងសម្រេចបានលទ្ធផលជាច្រើនដូចជា៖ ១) ចងក្រងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចំនួន ១៥៥ នាក់ ២)រៀបចំមេរៀន និងផ្តល់វគ្គបណ្តុះបណ្តាលពីគណនេយ្យភាពសង្គមដល់អង្គការដៃគូ និងមន្ត្រីពាក់ព័ន្ធថ្នាក់ស្រុកចំនួន ៣៨ នាក់ (ស្ត្រីចំនួន៣១%) ៣) រៀបចំកិច្ចប្រជុំផ្សព្វផ្សាយនៅក្នុងឃុំគោលដៅទាំង៤៣ ដែលមានអ្នកចូលរួមសរុបចំនួន ១,២២០នាក់(ស្ត្រី៣៨%) ៤)រៀបចំកិច្ចប្រជុំប្រជាពលរដ្ឋចំនួន ១២៩ដង ដើម្បីដាក់ពិន្ទុលើសេវាមណ្ឌលសុខភាព សាលាបឋមសិក្សា និងសេវាឃុំ ៥) រៀបចំកិច្ចប្រជុំរួមគ្នាតាមវិស័យចំនួន ១២៦ ដង មានប្រជាពលរដ្ឋចូលរួមសរុប ១,២៧១ នាក់ (ស្ត្រី ៦០%) ៦) រៀបចំកិច្ចប្រជុំរួមពហុវិស័យចំនួន៤៣ ដង ដែលមានប្រជាពលរដ្ឋចូលរួមសរុប៤៤៧ នាក់ (ស្ត្រី ៥១%) និង ៧)រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងដើម្បីផ្សព្វផ្សាយលទ្ធផល និងចែករំលែកបទពិសោធន៍គម្រោងក្រោមអធិបតីភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងចូលរួមពីក្រុមប្រឹក្សាតំណាងអង្គការសហគមន៍មូលដ្ឋាន(ស៊ីប៊ីអូ) និងអង្គការនានា។

ក្រោយពីបានឆ្លងកាត់ដំណើរការដាក់ពិន្ទុ និងពិភាក្សាផ្ទាល់ជាមួយប្រជាពលរដ្ឋ អ្នកផ្តល់សេវាភាគច្រើនបង្ហាញឥរិយាបទវិជ្ជមាន និងទទួលយកយោបល់ពីប្រជាពលរដ្ឋ ហើយដាក់ពិន្ទុ និងសំណូមពរឱ្យបន្តអនុវត្តជារៀងរាល់ឆ្នាំ។



ក្រុមប្រឹក្សាឃុំ និងមន្ត្រី ចូលរួមដាក់ពិន្ទុការផ្តល់សេវារបស់ខ្លួន (ឃុំស្នាអន្សា ស្រុកក្រគរ)

អង្គការផេក នៅកម្ពុជា
មជ្ឈមណ្ឌលភ្នំពេញ អាគារ អេ ជាន់ទី ៣
កែងមហាវិថីព្រះសីហនុ (២៧៤) និង
ព្រះសុធារស រាជធានីភ្នំពេញ
គេហទំព័រ
www.pactcambodia.org

## ការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សា

ក្រុមការងារផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង និងស្រុកសង្កែ ដោយមានការសម្របសម្រួលពីអង្គការអមរា បានផ្សព្វផ្សាយព័ត៌មានតាមឧឃោសនស័ព្ទ (មេក្រូ) ចល័តដល់ប្រជាពលរដ្ឋបានចំនួន ៣១ដង ក្នុង៣៩ឃុំ និងសង្កាត់ពីថ្ងៃទី១ ខែមករា ដល់ទី៣១ ខែមីនា ឆ្នាំ២០១៥ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិទទួលព័ត៌មាន និងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពក្រុមប្រឹក្សាក្រុងស្រុក។ ការផ្សព្វផ្សាយផ្ដោតលើតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា កម្មវិធីវិនិយោគក្រុងស្រុក ការប្រើប្រាស់ថវិកា តម្លៃសេវាសាធារណៈ និងសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពក្រុមប្រឹក្សា។



*សកម្មភាពផ្សព្វផ្សាយព័ត៌មានតាមមេក្រូចល័ត (ស្រុកសង្កែ)*

## អនុសាសន៍អង្គការសង្គមស៊ីវិលសម្រាប់ ផអ៣

ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGDP) នៃគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ដើម្បីចែករំលែកបទពិសោធន៍ និងបញ្ហាប្រឈមអនុវត្តការងារលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្របីឆ្នាំ ដំណាក់កាលទី១ និងផ្ដល់យោបល់លើការរៀបចំផែនការយុទ្ធសាស្ត្របីឆ្នាំ (ផអ៣) ដំណាក់កាលទីពីរ (២០១៥-២០១៧) នៃ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អ្នកចូលរួមសរុប ៥៥នាក់ មកពីសមាជិក WGPD និងបណ្ដាញអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)។

ក្រោយពីសិក្ខាសាលា WGDP បានចងក្រងអនុសាសន៍ និងដាក់ជូនលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បីបញ្ចូលក្នុងផអ៣ ដំណាក់កាលទីពីររួមមានៈ ស្នើសុំផ្ទេរមុខងារ ធនធានមនុស្ស និងថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានឆាប់និងកំណត់ពេលវេលានៃការផ្ទេរឱ្យបានច្បាស់លាស់ និងបង្កើនភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល ជាមួយ នឹងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា ។ល។

## បញ្ហា និងដំណោះស្រាយនៅសហគមន៍

គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈអង្គការដៃគូ ក្នុងខេត្តគោលដៅ (ពោធិ៍សាត់ បាត់ដំបង កំពង់ចាម និងមណ្ឌលគិរី) បានគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ចំនួន៦៣ ក្នុងក្រុងស្រុក៨ រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់បានចំនួន ៩ដង កិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សា ៣៦ដង និងឃុំសង្កាត់ ១៨៤ដង ម៉ោងជួបប្រជាពលរដ្ឋ ១៩ដង និងកិច្ចពិគ្រោះយោបល់មូលដ្ឋាន ៤៤ដងក្នុងរយៈ ៦ខែ (តុលា ២០១៤ ដល់មីនា ២០១៥)។ តាមរយៈសកម្ម ភាពខាងលើ ក្រុមប្រឹក្សាបានឆ្លើយតបចម្ងល់ប្រជាពលរដ្ឋ និងចាត់វិធានការដោះស្រាយបញ្ហាដែលប្រជាពលរដ្ឋបានលើក ក្រោយពីវេទិកាផងដែរ។ បញ្ហា និងដំណោះស្រាយមួយចំនួនមានដូចជា ១)ការកាប់បំផ្លាញព្រៃលិចទឹករបស់សហគមន៍ភូមិក្រងវែង ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលលើកដោយលោក ប៉ែន សុខុម តំណាងសហគមន៍ព្រៃឈើ ហើយក្រុមប្រឹក្សាឃុំ ស្នាអន្សាសហការជាមួយមន្ត្រីរដ្ឋបាលជលផល ប៉ូលីស និងប្រធានភូមិ ចុះផ្សព្វផ្សាយច្បាប់ជលផល និងបង្កើតក្រុមល្បាត ការពារតំបន់ព្រៃ លិចទឹកសហគមន៍ នៅខែវិច្ឆិកា ឆ្នាំ២០១៤។ ២) តម្រូវការកន្លែងរង់ចាំ សម្រាប់អ្នកជំងឺនៅមណ្ឌលសុខភាពឃុំវត្តតាមឹម ស្រុកសង្កែ ត្រូវបានប្រធានមណ្ឌលសុខភាពសហការជាមួយក្រុមប្រឹក្សា និងស្ថាប័នពាក់ព័ន្ធដោះស្រាយជូនប្រជាពលរដ្ឋ នៅខែតុលា ឆ្នាំ២០១៤ ដោយបានសង់អគារទំហំ ១០ម៉ែត្រគុណ នឹង៦ម៉ែត្រ)។ ៣)នៅខែវិច្ឆិកា ឆ្នាំ ២០១៤ លោក ឡុង វិបុល អភិបាលក្រុងសែនមនោរម្យ សហការជាមួយមន្ត្រី និងប៉ូលីស សង្កាត់សុខដុម ដោះស្រាយបានជោគជ័យ ដោយបញ្ឈប់ក្រុមហ៊ុនឯកជន ឈូសឆាយពង្រីកផ្លូវ ប៉ះពាល់ដល់ផ្នូរដូនតា ចំនួន ២៩ និងកន្លែងទីសក្ការៈ នៅភូមិស្វាយចេក ដែលតំណាងប្រជាពលរដ្ឋជនជាតិដើមភាគតិចទាមទារ និងបានលើកក្នុងវេទិកាសាធារណៈ។

បញ្ហាចំនួន ១២ ផ្សេងទៀតដែលក្រុមប្រឹក្សាក្រុងស្រុក ឃុំសង្កាត់សហការជាមួយអាជ្ញាធរពាក់ព័ន្ធដោះស្រាយបានដូចជាៈ ជម្លោះព្រំដី ការចោលសំរាមពាសវាលពាសកាល ដីហុយបណ្ដាលមកពីឡានដឹកដី ការជួសជុលផ្លូវលំ ធារាសាស្ត្រ ការខ្វះខាតគ្រាប់ពូជ តម្លៃភ្លើងអគ្គិសនីថ្លៃ និងភាពយឺតយ៉ាវនៃការធ្វើអត្តសញ្ញាណប័ណ្ណ។

## ការប្រមូលបញ្ហារបស់សហគមន៍

ក្នុងរយៈពេល ៣ខែដើមឆ្នាំ ២០១៥ ប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន យុវជន ក្រុមជនងាយរងគ្រោះ និងព្រះសង្ឃចំនួន ៣២៩ នាក់ និងអង្គ (ស្ត្រី១៧៩ នាក់) ក្នុងក្រុងពោធិ៍សាត់ និងស្រុកក្រគរ បានជួបជុំគ្នា ក្នុងវេទិកាសហគមន៍ចំនួន ៤ដង តាមរយៈការគាំទ្រពីអង្គការផែក និងអនាគតកុមារ។ ការជួបជុំគ្នានេះ ដើម្បីពិភាក្សា និងប្រមូលបញ្ហាប្រជាពលរដ្ឋដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំសង្កាត់ ក្រុងស្រុក ដោះស្រាយ។ បញ្ហាចំនួន ១១៥ករណីបានរកឃើញ និងដាក់ជូនក្រុមប្រឹក្សា។ ក្រុមប្រឹក្សាបានសន្យាយកបញ្ហាទាំងនោះ ទៅពិភាក្សា និងរៀបចំផែនការដោះស្រាយ ដោយបញ្ហាចំ៧ដាក់ក្នុងកម្មវិធីវិនិយោគ និងបញ្ហាដែលមិនអាចដោះស្រាយបានក្រុមប្រឹក្សាបញ្ជូនទៅខេត្តដើម្បីដោះស្រាយ។



*យុវជនតំណាងក្រុមស្ត្រីបង្ហាញបញ្ហាដែលបានពិភាក្សា (ក្រុងពោធិ៍សាត់)*